# ជំងឺ *Pestalotiopsis sp.*

## ១. លក្ខណៈទូទៅរបស់ជំងឺ

ជំងឺ *Pestalotiopsis sp.* ជាប្រភេទជំងឺម្សៅដែលបង្ករោគសញ្ញាទៅលើស្លឹករបស់រុក្ខជាតិ។ *Pestalotiopsis sp.* មានជាង២២០ប្រភេទ ដែលក្នុងនោះ២៣ប្រភេទ ត្រូវបានរកឃើញថាជាពពួកអង់ដូហ្វិត (endophytes) ប៉ុន្តែជំងឺនេះមិនមានជម្រកជាក់លាក់លើសារពាង្គកាយណាមួយទេ។ ចំពោះការបង្ករោគលើដំណាំកៅស៊ូវិញ ជំងឺនេះត្រូវបានប្រទះឃើញនៅក្នុងថ្នាលបណ្តុះកូនកៅស៊ូជាលើកដំបូង នៅក្នុងប្រទេសម៉ាឡេស៊ីនៅឆ្នាំ១៩៧៥។ បន្ទាប់មក គេឃើញមានកើតនៅកោះស៊ូម៉ាត្រា ខាងជើងប្រទេសឥណ្ឌូនេស៊ីនៅឆ្នាំ២០១៦ និងបានកើតឡើងនៅលើចម្ការកៅស៊ូគ្រួសារ ក្នុងប្រទេសម៉ាឡេស៊ីនៅឆ្នាំ២០១៧។ ដើមកៅស៊ូដែលកើតជំងឺនេះនឹងជ្រុះស្លឹកជាបណ្តើរៗស្ទើតែអស់ ដែលជាហេតុបណ្តាលអោយទិន្នផលជ័រធ្លាក់ចុះ។ នៅពេលថ្មីៗនេះ ជំងឺនេះបានរីករាលដាលយ៉ាងឆាប់រហ័ស ដោយបានបំផ្លាញចម្ការកៅស៊ូប្រមាណជាង៣សែនហិកតា នៅប្រទេសឥណ្ឌូនេស៊ីជាង៥ម៉ឺនហិកតានៅប្រទេសថៃ និងជាង២ពាន់ហិកតានៅប្រទេសម៉ាឡេស៊ី មិនតែប៉ុណ្ណោះ វាក៏កំពុងមានវត្តមាននៅក្នុងប្រទេសឥណ្ឌានិងប្រទេសស្រីលង្កាផងដែរ។

## ២. ភ្នាក់ងារបង្កនិងរោគសញ្ញាជំងឺ

ជំងឺ *Pestalotiopsis sp.* មានការរីករាលដាលយ៉ាងរហ័សក្នុងលក្ខខណ្ឌអាកាសធាតុ ត្រូពិចនិងបង្កដោយផ្សិតឈ្មោះ *Pestalotiopsis species*។ ជាទូទៅជំងឺ *Pestalotiopsis sp.* មានកើតឡើងទាំងនៅលើស្លឹកមិនទាន់ពេញវ័យ និងស្លឹកពេញវ័យដោយកើតឡើងស្ទើរគ្រប់ក្លូន កៅស៊ូទាំងអស់។ ចំពោះរោគសញ្ញាដែលកើតនៅលើស្លឹកកៅស៊ូមិនទាន់ពេញវ័យ ជាទូទៅមានស្នាមអុជតូចៗ ពណ៌លឿងត្នោតនិងខ្មៅ (ទំហំតូចជាង៥ម.ម.) ដែលអត្រាស្នាមអុជតិចឬច្រើនអាស្រ័យលើលក្ខខណ្ឌនិងការវិវឌ្ឍរបស់ជំងឺ។ បន្ទាប់មកស្នាមអុជនោះ ប្រែទៅជាពណ៌ប្រផេះដោយមានវណ្ឌពណ៌ខ្មៅនៅជុំវិញ។ ចំពោះស្លឹកពេញវ័យវិញ ស្នាមអុជនៅលើស្លឹកមានពណ៌ប្រផេះ និងទំហំអាចមានរហូតដល់១០ម.ម. ហើយស្នាមអុជទាំងនោះ អាចរីកទំហំនិងរលាយចូលគ្នាជាទម្រង់ស្នាមរលាក (leaf blight) បន្ទាប់មកកោសិកានៅត្រង់ស្នាមអុជនោះនឹងងាប់ (necrosis)។ ដើមកៅស៊ូចាស់ងាយទទួលរងការវាយប្រហារពីជំងឺជាងដើមកៅស៊ូនៅក្មេង។ ជាផលប៉ះពាល់នៅពេលដែលចម្ការកៅស៊ូមានកើតជំងឺ *Pestalotiopsis sp.* ស្លឹកកៅស៊ូជ្រុះរហូតដល់ប្រមាណជា៨០ ទៅ ៩០% ដែលជាហេតុធ្វើឲ្យទិន្នផលកៅស៊ូធ្លាក់ចុះ។

## ៣. ក្លូនកៅស៊ូនិងកម្រិតនៃជំងឺ

ផ្អែកទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីៗរបស់ក្រុមប្រឹក្សាកៅស៊ូ នៃប្រទេសម៉ាឡេស៊ីទាំងនៅក្នុងមន្ទីរពិសោធន៍ និងនៅលើចម្ការកៅស៊ូផ្ទាល់បានបង្ហាញថា មានក្លូនមួយចំនួនធន់នឹងការកើតជំងឺ ដូចមានបង្ហាញលំអិតក្នុងតារាងទី១ និងទី២ ខាងក្រោម៖

**តារាងទី១៖ លទ្ធផលពិសោធន៍លើភាពងាយឆ្លងនិងភាពធន់នឹងជំងឺរបស់ក្លូនកៅស៊ូ**

| ក្លូនកៅស៊ូ | កម្រិតនៃការបង្ករោគ |
|---|---|
| RRIM 600 | ខ្លាំង |

| | |
|---|---|
| RRIM 2007 | មធ្យម |
| RRIM 2023 | មធ្យម |
| RRIM 2024 | អត់ |
| RRIM 3001 | អត់ |
| RRIM 2025 | អត់ |
| RRIM 2001 | មធ្យម |
| RRIM 2008 | ស្រាល |

**តារាងទី២៖លទ្ធផលពិសោធន៍កម្រិតជម្ងឺលើក្លូនកៅស៊ូនៅលើទីតាំងមួយចំនួននៅប្រទេសម៉ាឡេស៊ី**

| ទីតាំងចម្ការពិសោធន៍ | ក្លូន | អាំងតង់ស៊ីតេជម្ងឺ | អត្រាស្លឹកជ្រុះ | អត្រាសំណុំស្លឹក | កម្រិតជម្ងឺ |
|---|---|---|---|---|---|
| Pancajaya Segamat | RRIM 600 | ខ្ពស់ | ៦០% - ៨០% | ៤០% - ២០% | ខ្លាំង |
| | RRIM 2023 | មធ្យម | ៤០% - ៦០% | ៦០% - ៤០% | មធ្យម |
| | RRIM 2025 | មធ្យម | ៤០% - ៦០% | ៦០% - ៤០% | មធ្យម |
| Labis | RRIM 2025 | មធ្យម | ៣០% - ៥០% | ៧០% - ៥០% | មធ្យម |
| Kluang | PB 260 | ខ្ពស់ | ៤០% - ៦០% | ៦០% - ៤០% | មធ្យម |
| | PB 350 | ខ្ពស់ | ៦០% - ៨០% | ៤០% - ២០% | ខ្លាំង |
| | RRIM 2001 | មធ្យម | ៣០% - ៥០% | ៧០% - ៥០% | មធ្យម |



*រូបភាពទី១៖ រោគសញ្ញាដែលបង្កឡើងនៅលើស្លឹក*

 

*រូបភាពទី២៖ ចម្ការកៅស៊ូដែលឈឺជ្រុះស្លឹក*

## ៤.ការការពារនិងការព្យាបាល

### ក. ការការពារ

ដើម្បីការពារឬកាត់បន្ថយអត្រាចម្លងជំងឺ *Pestalotiopsis sp.* មានវិធីសាស្ត្រមួយចំនួន ត្រូវបានណែនាំដូចជា៖

- ប្រើប្រាស់ក្លូនធននឹងជំងឺ
- អនុវត្តន៍កសិកម្មល្អ GAP (ការរៀបចំដី ការដាក់ជី ការកម្ចាត់ស្មៅ)
- ប្រើថ្នាំគីមីកសិកម្មការពារ។

**តារាងទី៣៖ ការប្រើប្រាស់ថ្នាំសម្លាប់ផ្សិតការពារជំងឺ**

| ថ្នាំសម្លាប់ផ្សិត | ប្រភេទថ្នាំ | កំហាប់ (ppm) (mg/l) | % នៃការទប់ទល់ |
|---|---|---|---|
| ក្លរូតាឡូនីល (Chlorothalonil) | ដោយប៉ះ (Contact) | 10<br>20<br>30<br>40<br>50 | 14<br>20<br>30<br>40<br>50 |
| ម៉ង់កូសែប (Mancozeb) | ដោយប៉ះ (Contact) | 10<br>20<br>30<br>40<br>50 | 12<br>16<br>20<br>30<br>40 |
| ប្រូពីណែប (Propineb) | ដោយប៉ះ (Contact) | 10<br>20<br>30<br>40<br>50 | 15<br>20<br>27<br>35<br>48 |
| ប្រូពីកូណាសូល (Propiconazole) | ជាប្រព័ន្ធ (Systemic) | 10<br>20<br>30<br>40<br>50 | 15<br>100<br>100<br>100<br>100 |

### ខ. ការព្យាបាល

ដើម្បីកំចាត់និងព្យាបាលជំងឺផ្សិតប្រភេទនេះ ថ្នាំកំចាត់ផ្សិតមួយចំនួនត្រូវបានណែនាំនិងប្រើប្រាស់ដូច

ខាងក្រោម៖

- ក្លរូតាឡូនីល (Chlorothalonil)
- ម៉ង់កូសែប (Mancozeb)
- ប្រូពីណែប (Propineb)
- ប្រូពីកូណាសូល (Propiconazole)

បាញ់ដោយ Blanket ឬ Ground Spraying ទូទាំងចម្ការ ពីដីរហូតដល់ចុងស្លឹកចំនួន ៣-៦ដង នៅចន្លោះពេលពី៧-១០ថ្ងៃ/១ដង។ ដោយឡែកនៅប្រទេសឥណ្ឌូនេស៊ី គេណែនាំឲ្យប្រើប្រាស់ថ្នាំសម្លាប់ផ្សិត Benomyl ចំនួន៨០ក្រាម/ហិចតា ដោយបាញ់ Spraying ទូទាំងចម្ការពីដីរហូតដល់ចុងស្លឹក។ ចំពោះការបាញ់ម្តងនៅប្រទេសម៉ាឡេស៊ីអស់ថវិកា RM100 - RM200/ha ប្រហែល ៣៦ដុល្លារ។



*រូបភាពទី៣៖ ការបាញ់ថ្នាំព្យាបាលជំងឺនៅក្នុងចម្ការ*